**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA

**ក្រសួងទេសចរណ៍**

**លេខ** ០០៤ សរណន

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០២០

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ ក្នុងដំណាក់កាលទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ (COVID-19)

អនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល ដែលមានក្រសួងសុខាភិបាលជាសេនាធិការក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩(COVID-19) និងជាពិសេសដើម្បីចូលរួមទប់ស្កាត់ការប៉ះពាល់អវិជ្ជមានលើវិស័យទេសចរណ៍ ក្រសួងទេសចរណ៍ បានដាក់ចេញនូវ **"វិធានសុវត្ថិភាពទេសចរណ៍"** ដើម្បីជួយសម្រួលដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ដែលកំពុងដំណើរការ ចូលរួមបង្ការ ការពារ និងរក្សាបាននូវសុវត្ថិភាព ទំនុកចិត្ត និងផ្តល់ភាពកក់ក្តៅជូនភ្ញៀវទេសចរដែលធ្វើដំណើរកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា។

សារាចរណែនាំនេះ ផ្តល់ការណែនាំបន្ថែមអំពីការអនុវត្តរបស់រដ្ឋបាលរាជធានី ខេត្ត ចំពោះខ្លឹមសារដូចមានកំណត់ក្នុងប្រកាសលេខ ០៤៥ប្រក. ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពី **"ការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត"** ក្នុងដំណាក់កាលនៃការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។

ដើម្បីធានាបាននូវការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ (COVID-19) ក្រសួងទេសចរណ៍សូមស្នើ **ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់រាជធានី ខេត្ត** សហការអនុវត្ត **"វិធានសុវត្ថិភាពទេសចរណ៍"** ដូចខាងក្រោម៖

**១.វិធានសុវត្ថិភាពទេសចរណ៍ដំណាក់កាលទី១** (ដូចមានឯកសារជូនភ្ជាប់) ដែលក្នុងនោះរួមមាន៖

- វិធានសុវត្ថិភាពទេសចរណ៍សម្រាប់សេវាកម្មស្នាក់នៅទេសចរណ៍
- វិធានសុវត្ថិភាពទេសចរណ៍សម្រាប់សេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍
- វិធានសុវត្ថិភាពទេសចរណ៍សម្រាប់សេវាកម្មដឹកជញ្ជូនទេសចរណ៍ផ្លូវទឹក
- វិធានសុវត្ថិភាពទេសចរណ៍សម្រាប់សេវាកម្មដឹកជញ្ជូនទេសចរណ៍ផ្លូវគោក
- វិធានសុវត្ថិភាពទេសចរណ៍សម្រាប់រមណីយដ្ឋានទេសចរណ៍
- វិធានសុវត្ថិភាពទេសចរណ៍សម្រាប់សហគមន៍ទេសចរណ៍។

**២.អំពីយន្តការ**

២.១. បង្កើតក្រុមការងារជំរុញ ណែនាំ និងតាមដានការអនុវត្ត **"វិធានសុវត្ថិភាពទេសចរណ៍"** ដែលដឹកនាំដោយ **ឯកឧត្តម លោកជំទាវអភិបាលរាជធានី ខេត្តផ្ទាល់** និងមានលេខាធិការដ្ឋានមួយជាសេនាធិការដែលមានប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្តជាប្រធានលេខាធិការដ្ឋាន និងមានតំណាងអង្គភាពពាក់ព័ន្ធជាសមាជិកតាមការចាំបាច់។

២.២. ក្រុមការងារនេះ មានភារកិច្ចជំរុញការអនុវត្ត **"វិធានសុវត្ថិភាពទេសចរណ៍"** ដែលដាក់ចេញដោយក្រសួងទេសចរណ៍ ក្នុងជំហានទី១ ដូចមានកំណត់ក្នុងចំណុចទី១ ខាងលើ។

២.៣. ក្រុមការងារនេះ ត្រូវមានអនុក្រុមការងារតាមការចាំបាច់នៅតាមក្រុង ស្រុក ខណ្ឌ ដែលមានអភិបាលក្រុង ស្រុក ខណ្ឌជាប្រធាន។ អនុក្រុមការងារនីមួយៗ ត្រូវអនុវត្តរបបរបាយការណ៍ទៀងទាត់មកប្រធានក្រុមការងារ (តាមការកំណត់របស់ប្រធានក្រុមការងារថ្នាក់រាជធានី ខេត្ត) តាមរយៈលេខាធិការដ្ឋាន។

**៣. អំពីការផ្សព្វផ្សាយខ្លឹមសារអនុវត្ត**

៣.១. ក្រុមការងារត្រូវផ្សព្វផ្សាយខ្លឹមសារអនុវត្តនេះដល់គ្រប់អង្គភាពចំណុះដើម្បីជ្រាប និងផ្តល់កិច្ចសការអនុវត្តតាមការចាំបាច់

៣.២. ក្រុមការងារ ត្រូវផ្សព្វផ្សាយខ្លឹមសារអនុវត្តនេះឱ្យដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ តាមរយៈ៖

- ការដាក់ជាលក្ខខណ្ឌតម្រូវអនុវត្តសម្រាប់ការផ្តល់អាជ្ញាបណ្ណទេសចរណ៍ថ្មី និងបន្ត
- ការផ្សព្វផ្សាយដល់គ្រប់មូលដ្ឋានអាជីវកម្មដែលទទួលបានអាជ្ញាបណ្ណទេសចរណ៍រួច និងមិនទាន់ដល់កាលបរិច្ឆេទត្រូវបន្ត ឱ្យកែសម្រួលលក្ខខណ្ឌអាជីវកម្មរបស់ខ្លួនក្នុងរយៈពេល **២០ថ្ងៃ (នៃថ្ងៃធ្វើការ)** បន្ទាប់ពីវិធានសុវត្ថិភាពទេសចរណ៍ត្រូវបានប្រកាសផ្សព្វផ្សាយជាផ្លូវការ។
- បន្ថែមលើនេះ ក្រុមការងាររាជធានី ខេត្ត ត្រូវផ្សព្វផ្សាយដល់គ្រប់មូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន។

**៤. អំពីនីតិវិធីអនុវត្ត**

៤.១. ក្រុមការងារថ្នាក់រាជធានី ខេត្ត ត្រូវចាត់តាំងឱ្យមានមន្ត្រីជំនាញចុះផ្សព្វផ្សាយនិងតាមដានការអនុវត្តជាប្រចាំនៅតាមឃុំ សង្កាត់

៤.២. ក្រុមការងារថ្នាក់រាជធានី ខេត្ត ត្រូវណែនាំមន្ត្រីជំនាញចុះអនុវត្ត ដូចខាងក្រោម៖

- រៀបចំកាលវិភាគចុះផ្សព្វផ្សាយ ដាក់ជូនប្រធានក្រុមការងារអនុម័តជាសកម្មភាពប្រចាំថ្ងៃដែលត្រូវអនុវត្ត
- ចុះអនុវត្តការងារប្រចាំថ្ងៃ និងត្រូវមានរបាយការណ៍ត្រួតពិនិត្យប្រចាំថ្ងៃគោរពជូនប្រធាន
- **ធ្វើរបាយការណ៍សរុបប្រចាំខែគោរពជូនប្រធានក្រុមការងារ**

៤.៣. ករណីអាជីវកម្មខកខានមិនបានអនុវត្តតាមការណែនាំ ក្រុមការងារថ្នាក់រាជធានី ខេត្ត ត្រូវណែនាំមន្ត្រីជំនាញចុះអនុវត្ត ដូចខាងក្រោម៖

- ចុះធ្វើកំណត់ហេតុដោយមានបញ្ជាក់ចំនុចខ្វះខាត និងត្រូវកំណត់ពេលវេលាឱ្យកែតម្រូវឱ្យបានច្បាស់លាស់។ ក្នុងរយៈពេលនេះ អាជីវកម្មត្រូវផ្អាកដំណើរការជាបណ្តោះអាសន្ន។
- នៅពេលកាលបរិច្ឆេទកំណត់មកដល់ មន្ត្រីជំនាញអាចចុះត្រួតពិនិត្យផ្ទាល់ម្តងទៀតដោយយោងលើកំណត់ហេតុ
- ប្រសិនបើអាជីវកម្មបានកែតម្រូវត្រឹមត្រូវ មន្ត្រីជំនាញអាចសម្រេចធ្វើនីតិវិធីផ្តល់ការអនុញ្ញាតឱ្យបើកដំណើរការឡើងវិញ
- ប្រសិនបើអាជីវកម្មនៅតែមិនអាចកែតម្រូវបានតាមការកំណត់ មន្ត្រីជំនាញត្រូវស្នើសុំគោលការណ៍សម្រេចពីប្រធានក្រុមការងាររាជធានី ខេត្ត សម្រេចឱ្យព្យួរអាជ្ញាបណ្ណទេសចរណ៍ក្នុងរយៈពេលណាមួយជាកំណត់រហូតដល់ពេលអាជីវកម្មអាចបំពេញតាមគ្រប់លក្ខខណ្ឌតម្រូវ។

៤.៤. ក្រុមការងារ ត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីការអនុវត្តនេះមក ក្រសួងទេសចរណ៍ និងត្រូវបញ្ជូនមកយ៉ាងយូរត្រឹមសប្តាហ៍ទី១នៃខែបន្ទាប់នីមួយៗ ដោយត្រូវភ្ជាប់នូវតារាងរាយនាមអាជីវកម្មដែល